ធ៧-០៤-២០៤ ប្រ.ក

# ប្រកាស
# ស្ដីពី
# ការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
# របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

**ប្រការ ១**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើនិងបញ្ជាក់ដោយសវនកម្មប្រចាំឆ្នាំ ហើយផ្ញើមកធនាគារជាតិនៃកម្ពុជាឱ្យបានមុន ថ្ងៃទី៣១ ខែមីនា នៃឆ្នាំប្រតិទិននីមួយៗ។ ស្នងការគណនីឯករាជ្យប្រតិស្រុតិត្រូវធ្វើសវនកម្ម និងផ្ដល់មតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ២**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានបញ្ជាក់ដោយសវនកម្ម ស្របតាមខ្លឹមសារដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយនេះ។

**ប្រការ ៣**.-

របាយការណ៍និងគណនី ដែលត្រូវចេញផ្សាយដូចមានក្នុងគោលការណ៍ណែនាំត្រូវចាប់ផ្ដើមពីឆ្នាំ ២០០៥ នេះតទៅ ហើយមិនត្រូវយឺតជាងថ្ងៃទី៣០ ខែមិថុនា នៃឆ្នាំប្រតិទិននិមួយៗ។ របាយការណ៍និងគណនី ដែលបានចេញផ្សាយ ត្រូវផ្ដល់ជូនអតិថិជននិងសាធារណជន។

**ប្រការ ៤**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមិនបានអនុវត្តតាមបទបញ្ជានេះត្រូវទទួលរងការដាក់ពិន័យស្រប តាមមាត្រា៥២ នៃច្បាប់ស្ដីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៥**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៦**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

# របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំស្របតាមបទដ្ឋានគណនេយ្យកម្ពុជា (CAS) និងការណែនាំធនាគារជាតិនៃកម្ពុជា។ នៅក្នុងករណីដែលបទដ្ឋានគណនេយ្យកម្ពុជាមិនបានបញ្ជាក់ អំពីប្រព្រឹត្តកម្មគណនេយ្យ ឬតម្រូវការបើកចំហព័ត៌មាន បទដ្ឋានរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ត្រូវបានប្រើជំនួស។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងរាល់ស្ថានភាពដែលមានទំនាស់កើតឡើងរវាងការណែនាំរបស់ធនាគារជាតិនៃកម្ពុជា និង CAS ឬ IFRS ការណែនាំរបស់ធនាគារជាតិនៃកម្ពុជាត្រូវបានទទួលស្គាល់ជាផ្លូវការ។

## ១. តារាងតុល្យការ

**១.១** ធនាគារត្រូវតែបង្ហាញនូវព័ត៌មានអប្បបរមានៅក្នុងតារាងតុល្យការ ឬក្នុងកំណត់សម្គាល់នៃរបាយ-ការណ៍ហិរញ្ញវត្ថុដូចខាងក្រោម:

**ទ្រព្យសកម្ម**

សមតុល្យជាមួយធនាគារកណ្តាល

សមតុល្យជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្សេងទៀត

ការដាក់ប្រាក់បញ្ញើ និងការផ្តល់ឥណទានទៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត

មូលប័ត្រ និង ប័ណ្ណរតនាគាររបស់រដ្ឋាភិបាល

មូលប័ត្រពាណិជ្ជកម្ម

ប័ណ្ណត្រូវទទួល

ការឱ្យខ្ចីចងការ និងបុរេប្រទានចំពោះអតិថិជន (កំណត់សម្គាល់ ១.៥)

សំវិធានធនលើបំណុលអាក្រក់ និងសង្ស័យ

- សំវិធានធនជាក់លាក់
- សំវិធានធនទូទៅ

ការវិនិយោគលើមូលប័ត្រដែលមានជាកម្មសិទ្ធិ (ធ្វើការវិភាគថាតើជាមូលនិធិ ឬបំណុល) ទ្រព្យសកម្មផ្សេងទៀត (ផ្តល់ព័ត៌មានលំអិតនៃខ្ទង់សំខាន់ៗ)

ប្រាក់ជំពាក់របស់ក្រុមហ៊ុនភាគទុនិក

ប្រាក់ជំពាក់របស់ក្រុមហ៊ុនបុគ្គលសម្ព័ន្ធ (ធ្វើវិភាគថាតើជាមូលធន ឬបំណុល)

ការវិនិយោគនៅក្នុងក្រុមហ៊ុនដែលជាសម្ព័ន្ធញ្ញាតិ (ធ្វើការវិភាគថាតើជាមូលប័ត្របំណុល ឬ មូលបត្រភាគហ៊ុន)

អចលនទ្រព្យ (កំណត់សម្គាល់ ១.៤)

ទ្រព្យសម្បត្តិដែលរឹបអូសពីកូនបំណុល (កំណត់សម្គាល់ ១.៤)

**ទ្រព្យអសកម្ម**

ប្រាក់បញ្ញើ និងសមតុល្យរបស់ធនាគារផ្សេងៗ

ប្រាក់បញ្ញើរបស់អតិថិជនមិនមែនជាធនាគារ

សំវិធានធនលើពន្ធ

ប័ណ្ណ និងរូបិយណត្តិត្រូវសង

ប្រាក់កំចីផ្សេងៗ (ដើម្បីផ្តល់នូវការបំបែកនៃខ្ទង់សំខាន់ៗ )

ភាគលាភដែលត្រូវសង

ប្រាក់ជំពាក់ក្រុមហ៊ុនភាគទុនិក

ប្រាក់ជំពាក់ក្រុមហ៊ុនបុត្តសម្ព័ន្ធ

មូលប័ត្របំណុលដែលបានចេញផ្សាយ (កំណត់សម្គាល់ ១.៣)

ប្រាក់ជំពាក់ភាគទុនិក

ដើមទុន និងប្រាក់បម្រុង

ដើមទុនរួមចំណែក (សាខាបរទេស)

ដើមទុន និងប្រាក់បម្រុង

ដើមទុនរួមចំណែក (សាខាបរទេស)

ភាគហ៊ុន (ដែលបានចុះបញ្ជី ចេញផ្សាយ និងទទួលស្គាល់)

ប្រាក់ខ្ចីបំពេញដើមទុន

ប្រាក់បម្រុង (ធ្វើការវិភាគទៅតាមប្រភេទនីមួយៗនៃទុនបម្រុង) ដោយរួមបញ្ចូលទាំងការវាយតម្លៃឡើងវិញទុនបម្រុង (កំណត់សម្គាល់ ១.២)

ប្រាក់ចំណេញរក្សាទុក/ការបង្គរខាត

១.២ ធនាគារត្រូវតែបង្ហាញចំនួននៃប្រាក់បម្រុងទៅតាមប្រភេទនីមួយៗនៅដើមឆ្នាំនិងចុងឆ្នាំនៃការិយបរិច្ឆេទគណនេយ្យ ព្រមទាំងចំនួននៃការផ្ទេរទៅ ឬ ផ្ទេរមកពីប្រភេទនីមួយៗនៃទុនបម្រុងនៅកំឡុងឆ្នាំ។

| | ភាគហ៊ុនធម្មតា | ទុនបម្រុងធនាគារទូទៅ | ទុនបម្រុង | ការវាយតម្លៃឡើងវិញនៃមូលប័ត្រភាគហ៊ុនរយៈពេលវែងដែលអាចលក់បាន | ប្រាក់ចំណេញរក្សាទុក |
|---|---|---|---|---|---|
| សមតុល្យដើមគ្រា<br>+ការផ្ទេរចូលទុនបម្រុង<br>-ការដកចេញពីទុនបម្រុង<br>សមតុល្យចុងក្រោយ | | | | | |

១.៣ ចំពោះមូលប័ត្របំណុលចេញផ្សាយដោយធនាគារដែលមានឥណប្រតិទានដំបូងច្រើនជាង ១ឆ្នាំ ធនាគារត្រូវបង្ហាញអត្រាការប្រាក់ (ចំពោះមូលប័ត្រដែលអត្រាការប្រាក់ថេរ) ឬ វិធីសាស្ត្រកំណត់អត្រាការប្រាក់ (ចំពោះមូលប័ត្រដែលមានអត្រាការប្រាក់អណ្តែត) និងកាលបរិច្ឆេទទូទាត់សង។

១.៤ ធនាគារត្រូវបង្ហាញពីតម្លៃទីផ្សារនៃការវិនិយោគ ទ្រព្យសម្បត្តិរបស់ធនាគារ និងទ្រព្យសម្បត្តិដែលរឹបអូសកូនបំណុល។ (ស្របនឹងតម្រូវការនៃប្រកាសលេខ ធ៧-០១-១៨៧ ប្រក ស្តីពីអចលនទ្រព្យរបស់ធនាគារ)

១.៥ ឱ្យខ្ចីចងការ និងបុរេប្រទានទៅអតិថិជន

| | សមតុល្យដើមគ្រា | សមតុល្យចុងក្រោយ |
|---|---|---|
| ឥណទានទៅរដ្ឋាភិបាល<br>- រាជរដ្ឋាភិបាល<br>- ផ្សេងៗ | | |
| ឥណទានពាណិជ្ជកម្ម<br>- ឥណទានវិបារូបន៍<br>- ឥណទានរយៈកាលខ្លី<br>- ឥណទានរយៈកាលវែង<br>- ឥណទានភតិសន្យា<br>- ឥណទានសម្ព័ន្ធញាតិ<br>- ឥណទានពាណិជ្ជកម្មផ្សេង ៗ | | |
| ឥណទានចំពោះអ្នកប្រើប្រាស់<br>- អចលនទ្រព្យ<br>- ឥណទានវិបារូបន៍<br>- ឥណទានចំពោះអ្នកប្រើប្រាស់<br>- ផ្សេងៗ | | |
| ឥណទានសរុប | | |

ចំពោះខ្លឹមសារនៃ " ឥណទានសម្ព័ន្ធញាតិ " ដែលមានចែងក្នុងមាត្រាទី៤៩ និង ៥០ ក្នុងជំពូក១៦ នៃច្បាប់ស្តីពី **គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**។

១.៦ ធនាគារត្រូវបង្ហាញចំនួនសរុបដុលនៃឥណទានដំណើរការ និងឥណទានមិនដំណើរការ (បំណុលដែលមានការធានា និងបំណុលមិនមានការធានា) ដែលបានកំណត់ជា បំណុលជា

ស្តង់ដារ បំណុលក្រោមស្តង់ដារ បំណុលសង្ស័យ និងបំណុលបាត់បង់ ស្របតាមប្រកាសលេខ ធ៧-០០-៥១ ស្តីពីចំណាត់ថ្នាក់ និងសំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យ និង ប្រកាសលេខ ធ៧-០២-១៤៥ ស្តីពី វិសោធនកម្មលើប្រកាសលេខ ធ៧-០០-៥១ មាន [ជំនួស ដោយ ធ៧-០៩-០៧៤ ប្រក ស្តីពី ការធ្វើចំណាត់ថ្នាក់ និងសំវិធានធនលើទ្រព្យសកម្មរបស់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ]

| | សមតុល្យចុងក្រោយ | សមតុល្យចុងគ្រា |
|---|---|---|
| បំណុលស្តង់ដារ | | |
| - មានការធានា | | |
| - មិនមានការធានា | | |
| បំណុលក្រោមស្តង់ដារ | | |
| - មានការធានា | | |
| - មិនមានការធានា | | |
| បំណុលសង្ស័យ | | |
| - មានការធានា | | |
| - មិនមានការធានា | | |
| បំណុលបាត់បង់ | | |
| - មានការធានា | | |
| - មិនការធានា | | |

១.៧ ធនាគារត្រូវផ្តល់នូវតារាងដែលបង្ហាញពីបំរែបំរួលសមតុល្យ នៃសំវិធានធននៅដើមគ្រាដកចេញ ឬបូកបញ្ចូលក្នុងគណនីចំណេញ-ខាតនៅក្នុងឆ្នាំ ចំនួនទឹកប្រាក់ប្រើប្រាស់សម្រាប់លុបចោល បំណុលអាក្រក់ប្រចាំឆ្នាំ និងសមតុល្យចុងគ្រា ដែលអនុវត្តតាម :

- សំវិធានធនជាក់លាក់សម្រាប់បំណុលបាត់បង់
- សំវិធានធនជាក់លាក់សម្រាប់ការថយចុះតម្លៃនៃការវិនិយោគ និងទ្រព្យសកម្មដទៃទៀត
- សំវិធានធនទូទៅ សម្រាប់បំណុលបាត់បង់ដែលអាចកើតឡើង និងហានិភ័យធនាគារ ផ្សេងទៀត តារាងស្រដៀងគ្នាដែលបង្ហាញពីបំរែបំរួលនៃការប្រាក់ព្យួរទុក ធនាគារត្រូវ ផ្តល់ឱ្យផងដែរ។

១.៨ ទ្រព្យសកម្មដែលបានសន្យាជាវត្ថុធានាជាមួយភាគីទីបី រួមទាំងចំនួនសរុបនៃបំណុលដែលមាន ការធានាត្រូវធ្វើការបង្ហាញផងដែរ។

## ២.របាយការណ៍ចំណេញ-ខាត

ធនាគារត្រូវតែបង្ហាញនូវព័ត៌មានអប្បបរមានៅក្នុងរបាយការណ៍ចំណេញ-ខាត ឬក្នុងកំណត់សម្គាល់ របាយការណ៍ហិរញ្ញវត្ថុ ដូចខាងក្រោម:

- ចំណូលពីការប្រាក់
- ចំណាយការប្រាក់
- ចំណូលពីការប្រាក់សុទ្ធ
- ចំណូលពីប្រតិបត្តិការផ្សេងៗ
    - ចំណេញ(ខាត) ពីសកម្មភាពជួញដូរ (ធ្វើការវិភាគលើចំណូលដែលបានមកពីការជួញដូរ រូបិយប័ណ្ណ មូលប័ត្រ និងឧបករណ៍ហិរញ្ញវត្ថុដោយឡែកពីគ្នា។
    - ថ្លៃឈ្នួល និងកំរៃជើងសារ
    - ភាគលាភ (ធ្វើការវិភាគលើចំណូលភាគលាភដែលបានមកពីបុគ្គលសម្ព័ន្ធ មកពីក្រុមហ៊ុនដែលជាសម្ព័ន្ធញាតិ និងមកពីការវិនិយោគផ្សេងទៀតដោយឡែកពីគ្នា)។
    - ថ្លៃជួល
    - ចំណេញ (ខាត) ពីការលក់មូលប័ត្រវិនិយោគ
    - ចំណូលផ្សេងៗ

**ចំណាយលើប្រតិបត្តិការផ្សេងៗ**

- ការចំណាយលើបុគ្គលិក (រួមបញ្ចូលទាំងប្រាក់លើកទឹកចិត្ត)
- ការចំណាយលើអគ្គនាយក និងអត្ថប្រយោជន៍បន្ថែម
- ប្រាក់កំរៃរបស់សវនករ
- រំលស់លើទ្រព្យសកម្មអរូបិយ
- ការថែរក្សា និងការជួលនៃអចលនទ្រព្យ
- ការចំណាយលើអាគារ (ការថែរក្សានិងការធានារ៉ាប់រង)
- ការចំណាយផ្សេងៗ
- ចំណាយលើសន្តិសុខ (ធានារ៉ាប់រងលើការដឹកជញ្ជូនសាច់ប្រាក់ ការថែរក្សាអាគារ និងអតិថិជន)។

**ប្រាក់ចំណេញពីប្រតិបត្តិការ**

សំវិធានធនសម្រាប់ឥណទានបាត់បង់ដែលអាចកើតមាននិងការថយចុះតម្លៃនៃទ្រព្យសកម្មដទៃទៀត

- សំវិធានធនជាក់លាក់សម្រាប់បំណុលបាត់បង់
- សំវិធានធនជាក់លាក់សម្រាប់ការថយចុះតម្លៃនៃការវិនិយោគ និងទ្រព្យសកម្មដទៃទៀត
- សំវិធានធនទូទៅ រួមបញ្ចូលទាំងសំវិធានធនសម្រាប់បំណុលបាត់បង់ដែលអាចកើតមាន និងហានិភ័យធនាគារដទៃទៀត
- ការប្រមូលបានមកវិញនូវសំវិធានធន និងចំណាយដែលបានលុបចោលពីគ្រាមុន
- ចំនួនដែលបានលុបចោល

ការបែងចែកប្រាក់ចំណេញ (ខាត) នៃក្រុមហ៊ុនសម្ព័ន្ធញាតិ

ចំណាយបង់ពន្ធ

ជំពូកវិសាមញ្ញ

ប្រាក់ចំណេញមិនសមស្របផ្ទេរមកពីឆ្នាំមុន

ភាគលាភ

- ភាគលាភបណ្តោះអាសន្ន
- ភាគលាភចុងក្រោយដែលបានស្នើ

ផ្ទេរទៅទុនបម្រុងទូទៅ

ប្រាក់ចំណេញមិនសមស្របផ្ទេរទៅគ្រាខាងមុខ

## ៣- របាយការណ៍លំហូរសាច់ប្រាក់

ធនាគារត្រូវតែរៀបចំរបាយការណ៍លំហូរសាច់ប្រាក់។

## ៤- ជំពូកក្រៅតារាងតុល្យការ

ធនាគារគួរតែបង្ហាញពីការបែងចែកខ្ទង់ក្រៅតារាងតុល្យការជាបីផ្នែកដូចតទៅ:

- កិច្ចសន្យាយថាភាព ត្រូវបង្ហាញចំនួនទឹកប្រាក់នៃកិច្ចសន្យាសម្រាប់ធាតុនីមួយៗខាងក្រោម ឬធាតុណាដែលមានចំណាត់ថ្នាក់ប្រហាក់ប្រហែលនឹងធាតុខាងក្រោម:
  - ជំនួយឥណទានផ្ទាល់
  - យថាភាពពាក់ព័ន្ធនឹងប្រតិបត្តិការ
  - យថាភាពពាក់ព័ន្ធនឹងពាណិជ្ជកម្ម
  - កិច្ចសន្យាយថាភាពផ្សេងៗ
- ការសន្យាត្រូវបង្ហាញពីចំនួនទឹកប្រាក់នៃខ្ទង់នីមួយៗដែលបានសន្យាដូចខាងក្រោម:
  - កម្រិតឥណទានមិនបានដក និងការសន្យាពន្យារពេលឥណទានផ្សេងៗ
  - កិច្ចសន្យាផ្តល់ឥណទានដែលមិនបានដកប្រើ និងការបន្តលើកិច្ចសន្យាផ្តល់ឥណទាន
  - ការទិញ ឬលក់ទ្រព្យសកម្ម និងការដាក់ប្រាក់បញ្ញើនៅពេលអនាគត
  - ការសន្យាផ្សេងៗ
- ឧបករណ៍ហិរញ្ញវត្ថុនិទស្សន្ទន៍ដែលមានជារូបិយប័ណ្ណបរទេស អត្រាការប្រាក់និងដើមទុន ដុំមាស ឬ ប្រាក់ និងទំនិញប្រើប្រាស់ផ្សេងៗ រួមទាំងកិច្ចសន្យាផ្សេងៗដែលពាក់ព័ន្ធ។ កិច្ចសន្យាទាំងនោះមានការទិញ-លក់រូបិយប័ណ្ណ និងផលប័ត្រនាពេលអនាគត ការដោះដូររូបិយប័ណ្ណ និងអត្រាការប្រាក់ ការយល់ព្រមកំណត់អត្រាការប្រាក់នាពេលអនាគត សិទ្ធិទិញ ឬលក់ដែលកំណត់តម្លៃជាក់លាក់សម្រាប់ពេលខាងមុខ។ ក្នុងករណីចាំបាច់ធនាគារត្រូវបង្ហាញនូវចំនួនទឹកប្រាក់នៃកិច្ចសន្យាតម្លៃទីផ្សារដុលវិជ្ជមាន ឬអវិជ្ជមាន និងមានឥទ្ធិពលនៃកិច្ចព្រមព្រៀងសរុបដែលអាចអនុវត្តបានតាមផ្លូវច្បាប់ចំពោះខ្ទង់នីមួយៗ។ ក្នុងករណីចាំបាច់ព័ត៌មានដូចគ្នានេះត្រូវបានឱ្យសម្រាប់ទំនិញប្រើប្រាស់ និងឥណទាននិទស្សន្ទន៍។ ត្រូវញែកឱ្យដាច់នៃប្រតិបត្តិការទៅលើឧបករណ៍និទស្សន្ទន៍រវាងប្រតិបត្តិការបញ្ចៀសហានិភ័យ និងប្រតិបត្តិការពាណិជ្ជ។

## ៥- គោលការណ៍គណនេយ្យ

ធនាគារត្រូវតែបង្ហាញឱ្យឃើញនូវគោលការណ៍គណនេយ្យសំខាន់ៗ ដែលបានអនុម័តក្នុងការរៀបចំ និងការបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុ។ ចំណុចខាងក្រោមត្រូវបង្ហាញក្នុងគោលការណ៍គណនេយ្យ ប៉ុន្តែមិនកំណត់ត្រឹមតែចំនុចទាំងអស់នេះទេៈ

- មូលដ្ឋាននៃការទទួលស្គាល់នូវប្រភពប្រាក់ចំណូលសំខាន់ៗ
- ការផ្លាស់ប្តូរវិធីសាស្រ្តគណនេយ្យក្នុងកំឡុងនៃឆ្នាំ ដែលក្នុងករណីនេះគណនីហិរញ្ញវត្ថុនៃឆ្នាំមុនត្រូវបានបង្ហាញជាមួយវិធីសាស្រ្តថ្មី
- មូលដ្ឋានសម្រាប់ធ្វើសំវិធានធនជាក់លាក់ទៅលើឥណទានបាត់បង់ និងធ្វើសំវិធានធនទូទៅសម្រាប់ហានិភ័យឥណទាន ឬសម្រាប់ហានិភ័យធនាគារដទៃទៀត
- វិធីសាស្រ្តនៃការវាយតម្លៃទៅលើមូលប័ត្រវិនិយោគ ការជួញដូរមូលប័ត្រនិងឧបករណ៍ហិរញ្ញវត្ថុនិទស្សន្ន័
- ការធ្វើរំលស់ទៅលើអចលនទ្រព្យ
- មូលដ្ឋាននៃការរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុ
- ការផ្ទេរតម្លៃទ្រព្យសកម្ម និងទ្រព្យអកម្មរូបិយប័ណ្ណបរទេសមកជារូបិយប័ណ្ណក្នុងស្រុក។

## ៦- ការកាត់ចំណែកនៃព័ត៌មាន

៦-១ ធនាគារត្រូវវិភាគឥណទាន និងបុរេប្រទានទៅតាមជំពូកនៃវិស័យដូចខាងក្រោម (ការប្រមូលផ្តុំនូវការផ្តល់ទុនទៅតាមវិស័យ)

- កសិកម្ម
- ឧស្សាហកម្ម
- សំណង់ និងការស្ថាបនា
- ផ្ទះ (ទិញ)
- លក់ដុំ និង លក់រាយ
- នាំចេញ
- នាំចូល
- ដឹកជញ្ជូន និងគមនាគមន៍
- សេវាកម្ម
- វិជ្ជាជីវៈ និងការប្រើប្រាស់ជាឯកជន (លើកលែងការឱ្យខ្ចីសម្រាប់ទិញផ្ទះ)
- ផ្សេងៗ

៦-២ ធនាគារត្រូវផ្តល់នូវការវិភាគឥណប្រតិទានសម្រាប់ការឱ្យខ្ចី (ទាំងធនាគារនិងមិនមែនធនាគារ) និងការដាក់ប្រាក់បញ្ញើ (ធនាគារ និងមិនមែនធនាគារ) ទៅតាមប្រភេទនៃកាលវសាន្ត ដូចខាងក្រោមៈ

- កាលវសាន្តរយៈពេល ១ឆ្នាំ
- ច្រើនជាង ១ឆ្នាំ តែតិចជាង ៣ឆ្នាំ
- ច្រើនជាង ៣ឆ្នាំ តែតិចជាង ៥ឆ្នាំ
- ច្រើនជាង ៥ឆ្នាំ

ការវិភាគទៅតាមប្រភេទនៃឥណប្រតិទាននីមួយៗត្រូវផ្អែកទៅលើពេលវេលាដែលនៅសល់រហូតដល់កាលវសាន្តតាមកិច្ចសន្យានៅក្នុងកាលបរិច្ឆេទតារាងតុល្យការ។

**៧- ការត្រួតពិនិត្យ**

ធនាគារត្រូវបង្ហាញព័ត៌មានដូចខាងក្រោមសម្រាប់គោលបំណងនៃការត្រួតពិនិត្យ ហើយព័ត៌មានទាំងនោះមិនចាំបាច់បោះផ្សាយសម្រាប់សាធារណជននោះទេ។

៧.១ បទប្បញ្ញត្តិប្រុងប្រយ័ត្ន

- ប្រកាសស្តីពីអនុបាតសាច់ប្រាក់ងាយស្រួលលេខ ធ៧-០០-៣៨ និងប្រកាសស្តីពីវិសោធនកម្មលេខ ធ៧-០២-១៨៧ ប្រក
  - ក-សាច់ប្រាក់ងាយស្រួល
  - ខ-ចំណាត់ថ្នាក់សាច់ប្រាក់ងាយស្រួល
- ប្រកាសស្តីពីមូលនិធិផ្ទាល់សុទ្ធ លេខ ធ៧-០០-៤៧ ប្រក [ ជំនួសដោយប្រកាស ធ៧-០១០-១៨២ ប្រក] ប្រកាសស្តីពីអនុបាតសាធនភាព ធ៧-០០-៤៦ ប្រក
- ប្រកាសស្តីពីសំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យ លេខ ធ៧-០០-៥១ [ ជំនួសដោយប្រកាស ធ៧-០៩-០៧៤ ប្រក ]

៧-២ ព័ត៌មានបន្ថែម (ឧបសម្ព័ន្ធ ២)

៧-៣ សូចនាករហិរញ្ញវត្ថុសំខាន់ៗ

- ដើមទុន
- ទ្រព្យសកម្ម
- ប្រាក់ចំណេញ
- សាច់ប្រាក់ងាយស្រួល

៧-៤ របាយការណ៍របស់អ្នកគ្រប់គ្រង

អនុសាសន៍របស់ស្នងការគណនេយ្យ កត់សម្គាល់ពីចំណុចខ្សោយដែលរកឃើញនៅក្នុងពេលធ្វើសវនកម្ម ប៉ុន្តែមិនកំណត់តែចំណុចដូចមានចែងខាងក្រោមទេ:

១- រាល់កិច្ចសន្យា និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខារវាងធនាគារ និងម្ចាស់ភាគហ៊ុន នាយកគ្រប់គ្រង និងភាគីដែលពាក់ព័ន្ធដទៃទៀត។

២- ការផ្លាស់ប្តូរអ្នកគ្រប់គ្រង (បុគ្គលិកជាន់ខ្ពស់ ភាពញឹកញាប់ មូលហេតុ និងជំលោះផលប្រយោជន៍ ជាសក្តានុពល ការតែងតាំងក្រុមប្រឹក្សាភិបាល)

៣- ការឧទ្ទេសនាមផលិតផលថ្មី (ការលក់មូលប័ត្រទេសចរណ៍ និងកិច្ចសន្យាដោះដូរ)

៤- កិច្ចសន្យាថ្មី (ភតិសន្យាថ្មី កិច្ចព្រមព្រៀងរវាងភ្នាក់ងារនិងធនាគារ)

៥- ការបើកសាខាថ្មី (មូលហេតុ គោលបំណង និងការចាត់តាំងបុគ្គលិក)

៦- គុណភាពនៃសំពៀតឥណទាន(ការប្រមូលផ្តុំឥណទាន តំបន់ឧស្សាហកម្ម និងបុគ្គល)

៧- ការវិនិយោគក្នុងឆ្នាំ (មូលហេតុ ការអនុម័ត កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល)
៨- ភាពគ្រប់គ្រាន់នៃសំវិធានធន
៩- ប្រតិបត្តិការកុំព្យូទ័រ (សុវត្ថិភាព ការរក្សាទុក បុគ្គលិក ប្រសិទ្ធភាព និងហានិភ័យ)
១០- ផែនការប្រមូលការខូចខាតមកវិញក្នុងពេលអាសន្ន
១១- គោលនយោបាយសម្រាប់ការគ្រប់គ្រងការប្រឈមមុខ នឹងហានិភ័យរូបិយវត្ថុ (ព័ត៌មានបែបបិរមាណ)
១២- ចំណុចខ្សោយដទៃទៀតដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ

**ឧបសម្ព័ន្ធទី២**

ប្រកាសលេខ ធ៧-០៤-០២៤

ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤

**ឈ្មោះធនាគារ**......................................................

(I). ធាតុនីមួយៗ នៃតារាងតុល្យការ

(ក).(១)

## សរុបឥណទានតាមចំណាត់ថ្នាក់ ដែលបានផ្តល់ឱ្យអតិថិជន

ចំនួនទឹកប្រាក់

-ក្រោមស្តង់ដារ ______

-សង្ស័យ ______

-បាត់បង់ ______

ដកៈ ទឹកប្រាក់ប៉ាន់ស្មានដែលអាចទាញមកវិញបាន ______

ទឹកប្រាក់ប៉ាន់ស្មានដែលមិនអាចទាញមកវិញបាន ______

(២) សំវិធានធនជាក់លាក់ សម្រាប់ឥណទានបាត់បង់និងសង្ស័យ

-ឱ្យខ្ចីចងការ និងបុរេប្រទាន ______

-ប័ណ្ណឥណទេយ្យ ______

(៣) សំវិធានធនទូទៅសម្រាប់ឥណទាន ______

(ខ). មូលប័ត្រវិនិយោគរយៈពេលខ្លីនិងរយៈពេលវែង

| ការពិពណ៌នា | ថ្លៃដើម | តម្លៃចារឹកសន្លឹកប័ណ្ណ | បុព្វលាភដែលចូលក្នុងខ្ទង់ចំណាយ | អប្បហារបង្គរទុកជាចំណូល | ការធ្លាក់ចុះនៃតម្លៃ | | តម្លៃក្នុងបញ្ជី | តម្លៃទីផ្សារ(ចំណាយការប្រាក់ក្នុងករណីមូលប័ត្របំណុល) |
|---|---|---|---|---|---|---|---|---|
| (១) ប័ណ្ណរតនាគាររបស់រដ្ឋាភិបាល | | | | | សំវិធានធនដែលបានធ្វើ | ចំនួនដែលបានលុបចោល | | |
| (២) ប័ណ្ណរតនាគាររបស់រដ្ឋាភិបាលដទៃទៀត | | | | | | | | |
| (៣)ការវិនិយោគលើក្រុមហ៊ុនដែលជាសាខា | | | | | | | | |
| (៤) ការវិនិយោគលើក្រុមហ៊ុនដែលពាក់ព័ន្ធ | | | | | | | | |
| (៥) ការវិនិយោគដទៃទៀត | | | | | | | | |
| - ការវិនិយោគជាដើមទុន | | | | | | | | |
| - ក្រដាសដទៃទៀត | | | | | | | | |

* មិនរួមបញ្ចូលប័ណ្ណអប្បហារ

(គ). អគារធនាគារ និងទ្រព្យសម្បត្តិដទៃទៀតដែលមិនអាចធ្វើចលនាបាន ចំនួន

(១) ថ្លៃដើមរបស់ទ្រព្យសម្បត្តិ ________

(២) ចំនួនដែលបានលុបចោល ________

(៣) សំវិធានធនសម្រាប់រំលស់ ឬការបាត់បង់ ________

(៤) តម្លៃទីផ្សារ ឬតម្លៃទីផ្សារដែលបានប៉ាន់ស្មាន (បង្ហាញកាលបរិច្ឆេទនិងការវាយតម្លៃចុងក្រោយបំផុតរបស់អ្នកវាយតម្លៃដែលមានវិជ្ជាជីវៈ) ។ បង្ហាញបញ្ជីទ្រព្យសម្បត្តិ អាសយដ្ឋាន និងសេចក្តីលំអិតដទៃទៀត[១] ________

(ឃ). ប្រាក់បម្រុងដើមទុន

(១) ប្រាក់បម្រុងបុព្វលាភរបស់សន្លឹកហ៊ុន ________

(២) ប្រាក់បម្រុងវាយតម្លៃ ________

(៣) ប្រាក់បម្រុងដើមទុនដទៃទៀត ________

(ង). ប្រាក់បម្រុងចំណូល[២]

(១) ប្រាក់បម្រុងកាតព្វកិច្ច ________

(២) ប្រាក់ចំណូលដទៃទៀត ________

(៣) ចំណេញ ឬខាតដែលមិនសមស្រប ________

(ច). សំវិធានធនដទៃទៀត និងការបម្រុងទុកសម្រាប់ការបាត់បង់ ឬយថាភាព ផ្តល់សេចក្តីលំអិត នៃការធ្វើសំវិធានធន និងប្រាក់បម្រុងដទៃទៀត " ដោយបញ្ជាក់ពីគោលបំណងនៃការបម្រុងទុកនោះ " ដែលបានបែងចែកទៅតាមខ្ទង់ (បំណុលដទៃទៀតដែលបានរួមបញ្ចូលសំវិធានធននិងការបម្រុងទុកដទៃទៀត) នៅក្នុងតុល្យការ។ ________

(ឆ). ផ្តល់ព័ត៌មានលំអិតដែលបានបញ្ចូលនៅក្នុងគណនីដទៃទៀត ________

(ជ). (១) ប្រាក់បញ្ញើសរុបរបស់អតិថិជនដែលមិនមែនធនាគារ ________

(២) ប្រាក់បញ្ញើ និងសមតុល្យរបស់ធនាគារ និងភ្នាក់ងារ ________

(ឈ). ប្រសិនបើអាចធ្វើបាន គួរតែភ្ជាប់មកជាមួយនូវខ្ទង់ដូចខាងក្រោម ________

(១) វាយឈ្មោះប្រភេទឥណទានប្រើប្រាស់ដោយក្រុមហ៊ុនដែលធនាគារកាន់កាប់ភាគហ៊ុនដោយផ្ទាល់ឬដោយប្រយោល។

---

[១] លុបចោលនៅពេលចាំបាច់

[២] -ប្រាក់បម្រុងកាតព្វកិច្ចដែលបានកំណត់នៅក្នុងប្រកាសលេខ ធ៧-០៩-០២០ ប្រ.ក

-ប្រាក់បម្រុងចំណូលដទៃទៀតគឺចំនួនដែលលើសពីប្រាក់បម្រុងកាតព្វកិច្ច

(២) របាយឈ្មោះឥណទាន និងប្រភេទឥណទានដទៃទៀតដែលបានផ្តល់ទៅឱ្យសម្ព័ន្ធញាតិ ដូចមានចែងក្នុងមាត្រា ៤៨-៥០ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

(៣) របាយឈ្មោះទ្រព្យសម្បត្តិរបស់ធនាគារ ដែលបានដាក់បញ្ចាំ ឬផ្ញើនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀត។ល។ ដូចជាវត្ថុធានាសម្រាប់មូលនិធិដែលបានផ្តល់ឱ្យធនាគារ ឬភាគីណាមួយ ដោយប្រើមធ្យោបាយជាប្រាក់បញ្ញើ ឥណទាន បុរេប្រទាន ឬមធ្យោបាយដទៃទៀត។

(II). របាយការណ៍ចំណេញ-ខាត

(១) របាយការណ៍ចំណេញ-ខាតដែលបានធ្វើសវនកម្មរួចមួយច្បាប់ ដែលបង្ហាញសេចក្តីលំអិតអំពីចំណូល និងចំណាយរបស់ធនាគារ និង

(២) ភ្ជាប់មកជាមួយនូវរបាយការណ៍ចំណេញ-ខាត មួយច្បាប់

---------------------------

នាយកប្រតិបត្តិ

---------------------------

នាយកគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ

យើងសូមអះអាងថា ព័ត៌មានហិរញ្ញវត្ថុដែលបានបញ្ជាក់ខាងលើអនុលោមទៅតាមបញ្ជី និងកំណត់ត្រាហិរញ្ញវត្ថុរបស់ធនាគារ ដែលបានរៀបចំឡើងផ្អែកលើមូលដ្ឋានសវនកម្មរបស់ធនាគារ។

---------------------------

ស្នងការគណនីឯករាជ្យ

## កំណត់សម្គាល់

២ ដើមទុនថ្នាក់ទី ១ = ដើមទុនបានបង់ជម្រះ (ភាគហ៊ុនធម្មតា) + ទុនបម្រុង

៣,៤ និង៦ ទ្រព្យសម្បត្តិដែលបានថ្លឹងហានិភ័យរួច សំដៅលើភាគយករបស់អនុបាតសាធនភាព។ សម្រាប់ព័ត៌មានលំអិត សូមមើលប្រកាសស្តីពី អនុបាតសាធនភាពរបស់ធនាគារ

៤ ដើមទុនថ្នាក់ ១ + ថ្នាក់២ = ដើមទុនបានបង់ជម្រះ(ភាគហ៊ុនធម្មតា) + ទុនបម្រុង + ទុនបម្រុងទូទៅ + បំណុលបំពេញដើមទុន + ដើមទុនកូនកាត់ (ភាគហ៊ុនអាទិភាព)

៩ ភាគលាភ សំដៅលើភាគលាភដែលបានបង់ក្នុងឆ្នាំ

១១ ទុនបម្រុងសម្រាប់ហានិភ័យធនាគារ សំដៅលើគណនីលេខ ៤០៥០០០ នៅក្នុងប្លង់គណនី

១៤,១៦ ទ្រព្យសម្បត្តិដែលបានចាត់ថ្នាក់សំដៅឥណទានមិនដំណើរការនិងទ្រព្យសម្បត្តិទាំងឡាយណាដែលចាំបាច់ត្រូវធ្វើសំវិធានធន

១៨ សម្រាប់និយមន័យនៃពាក្យ " ហានិភ័យធំៗ" សូមយោងទៅតាមប្រកាសលេខ ធ៧-០៦-២២៦ ស្តីពី ការត្រួតពិនិត្យហានិភ័យធំៗរបស់ធនាគារ។

២៤ សំវិធានធន = សំវិធានធនសម្រាប់ការខាតបង់ឥណទាននិងភតិសន្យា (គណនីលេខ ១៧០០០០) + សំវិធានធនសម្រាប់ការខាតបង់ឥណទានលើការវិនិយោគនិងមូលប័ត្រ (គណនីលេខ ២១៤០០០)។

៣១ សំវិធានធនកំណត់ដោយគណនីលេខ ៦៦១០០០ រួមមាន សំវិធានធនលើបំណុលអាក្រក់ និង បំណុលសង្ស័យលើប្រាក់ដើមនិងបង្គរការប្រាក់ សំវិធានធនសម្រាប់ការខាតបង់លើខ្ទង់ក្រៅតារាងតុល្យការ សំវិធានធនលើការខាតបង់ប្រាក់ដើមរបស់មូលប័ត្រ និងសំវិធានធនទូទៅ។

៣៤ ពន្ធ = ពន្ធប៉ាតង់ (៦៥៧១០០) + ពន្ធលើដីដែលមិនបានប្រើប្រាស់ (៦៥៧៤០០) + ពន្ធលើមធ្យោបាយដឹកជញ្ជូន (៦៥៨០០០) + ពន្ធលើប្រាក់ចំណេញ (៦៥៩១០០)។

៣៩ ទ្រព្យសម្បត្តិងាយក្លាយជាសាច់ប្រាក់ សូមយោងទៅខ្ទង់ឥណពន្ធដែលបានកំណត់នៅក្នុងប្រកាសលេខ ធ៧-០០-៣៨ ស្តីអំពី អនុបាតសាច់ប្រាក់ងាយស្រួល។

៤០ Quick Assets = សាច់ប្រាក់ + មាស + ប្រាក់បញ្ញើនៅធនាគារជាតិ (មិនរាប់បញ្ចូលប្រាក់ធានាលើដើមទុននិងប្រាក់បម្រុងកាតព្វកិច្ច)+ ប្រាក់បញ្ញើនៅធនាគារដទៃទៀត

# FINANCIAL SOUNDNESS INDICATORS

***CAPITAL***

1- Equity to Total Asset (A/B)
 A- Equity
 B- Total assets
2- Capital Tier I to Total Asset (A/B)
 A- Capital Tier I
 B- Total assets
3- Capital Tier I to Risk Weighted Asset (A/B)
 A- Capital Tier I
 B- Risk Weighted assets
4- Capital Tier 1 +Tier 2 to Risk Weighted Asset (A/B)
 A- Capital Tier 1 +Tier 2
 B- Risk Weighted assets
5- Net Worth to Total Assets (A/B)
 A- Net Worth
 B- Total assets
6- Solvency Ratio (A/B)
 A- Net Worth
 B- Risk Weighted assets
7- Debt to Total Asset (A/B)
 A- Total liabilities
 B- Total assets
8- Debt to Equity (A/B)
 A- Total liabilities
 B- Equity
9- Dividend to Net Profit (A/B)
 A- Dividend
 B- Net Profit

*ASSET QUALITY*

10- Banking Reserve to Total Loans (A/B)
 A- Banking Reserves
 B- Total Loans (gross)
11- Banking Reserve to Total Assets (A/B)
 A- Banking Reserves
 B- Total assets
12- NPL to Total Loan (A/B)
 A- NPL
 B- Total loan (gross)
13- NPL to Total Asset (A/B)
 A- NPL
 B- Total Asset
14- Classified Asset to Total Loan (A/B)
 A- Classified Asset
 B- Total loans (gross)
15- Classified Asset to Total Asset (A/B)
 A- Classified assets
 B- Total assets
16- Classified Asset to Equity (A/B)
 A- Classified assets
 B- Equity
17- Loan to Related Parties to Total Loan (A/B)
 A- Loan to Related Parties
 B- Total loans (gross)
18- Large Exposure to Total Loan (A/B)
 A- Large exposure
 B- Total loans (gross)
19- Loan to Related Party to Net Worth (A/B)
 A- Loan to related Parties
 B- Net Worth
20- Large Exposure to Net Worth (A/B)
 A- Large exposure
 B- Net Worth
21- General Provision to Total Loan (A/B)
 A- General Provision
 B- Total loans (gross)
22- Specific Provision to Total Loan (A/B)
 A- Specific Provision
 B- Total loans (gross)
23- Specific Provision to NPL (A/B)
 A- Specific provision
 B-NPL
24- All Allowances to Total Assets (A/B)
 A- Total all allowances
 B- Total assets

25- Loans to Deposits (A/B)
 A- Total loans to non-bank customers (gross)
 B- Customer's deposits

***EARNINGS***

26- ROA (A/B)
 A- Net profit
 B- Total assets
27- ROE (A/B)
 A- Net profit
 B- Equity
28- Gross Yield (A/B)
 A- Interest income
 B- Total assets
29- Net Interest margin (NIM) to Total Asset (A-B)/C)
 A- Interest income
 B- Interest expense
 C- Total assets
30- Other Income (OTINC) = (A/B)
 A- Other incomes
 B- Total assets
31- Provision to Total Assets (A/B)
 A- Provision
 B- Total assets
32- Overhead (OHEAD) = (A/B)
 A- Non-interest expenses
 B- Total assets
33- Net Income Before Tax (NIBT) = (A/B)
 A- Net income before tax
 B- Total assets
34- Tax to Total Assets (A/B)
 A-Tax
 B- Total assets
35- Interest Margin to Gross Income ((A-B)/C)
 A- Interest income
 B- Interest expense
 C- Gross income
36- Non-interest Income to Gross Income (A/B)
 A- Non-interest income
 B- Gross Income
37- Non-Interest Expense to Gross Income (A/B)
 A- Non-Interest expense
 B- Gross income
38- Times Interest earned ((A+B)/C)
 A- Income before tax
 B- Interest expense
 C- Interest expense

***LIQUIDITY***

39- Liquid Asset (A/B)
 A- Liquid asset
 B- Total assets
40- Short-term Liabilities (A/B)
 A- Short-term liabilities (less than one year)
 B- Total assets
41- Net Liquid Assets (A-B)/C
 A- Liquid assets
 B- Short-term liabilities
 C- Total liabilities
42- Quick ratio (A/B)
 A- Quick assets
 B- Current liabilities
43- Deposits to Total Loans (A/B)
 A- Total customers' deposits
 B- Total loans to non-bank customers (gross)

ឧបសម្ព័ន្ធទី៤

# គោលការណ៍សម្រាប់ធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុស្ដីពីជំពូកដែលត្រូវបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់ផ្សព្វផ្សាយជាសាធារណៈ

ធនាគារត្រូវបង្ហាញព័ត៌មានដូចខាងក្រោម :

១ របាយការណ៍របស់នាយកក្រុមប្រឹក្សាភិបាល

- បរិស្ថានអាជីវករទូទៅ
- របាយការណ៍សង្ខេបនៃប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ
- បង្ហាញដោយសង្ខេបពីផលិតផលថ្មីដែលធ្វើការឧទ្ទេសនាម ប្រសិនបើមាន
- សមត្ថភាពក្នុងការគោរពទៅតាមបទប្បញ្ញត្តិធនាគារជាតិ និងសកម្មភាពផ្សេងៗ
- ជំហានដែលបានអនុវត្តដើម្បីពង្រឹងប្រត្តិបត្តិការ និងជំហាររបស់ធនាគារ
- គោលដៅនិងកិច្ចសន្យារបស់ក្រុមប្រឹក្សាភិបាល

២ រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាភិបាល

- ការបែងចែកភារកិច្ច និងការទទួលខុសត្រូវនៅក្នុងធនាគារ
- ការរាយការណ៍ និងការគ្រប់គ្រង

៣ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

- របាយការណ៍គណនីគ្រប់គ្រង
- សកម្មភាពចំបងៗនៅក្នុងឆ្នាំ

៤ គោលនយោបាយ និងរបាយការណ៍សម្រាប់អភិបាលកិច្ចសាជីវកម្ម

- ការជ្រើសរើសគណគ្រប់គ្រង
- ក្រុមប្រឹក្សាភិបាល
    - ✓ សមាសភាពក្រុមប្រឹក្សាភិបាល
    - ✓ ប្រវត្តិសង្ខេបរបស់ក្រុមប្រឹក្សាភិបាល
    - ✓ ការប្រជុំក្រុមប្រឹក្សាភិបាល
- ការត្រួតពិនិត្យផ្ទៃក្នុង
- ការគ្រប់គ្រង់ហានិភ័យ
- ក្រុមសីលធម៌
- ឯករាជ្យភាព និងតម្លាភាព

៥. ការពិពណ៌នាពីអាជីវកម្ម

- សកម្មភាពចំបងៗរបស់ធនាគារ
- បេសកម្មនិងទស្សនៈវិស័យ
- ទស្សនៈវិទ្យារបស់ធនាគារ

- ✓ អតិថិជន
- ✓ និយោជិត
- ✓ បរិស្ថាន សង្គម និង សហគមន៍
- ✓ ភាគទុនិក

៦. សន្ទស្សន៍ហិរញ្ញវត្ថុ (សូចនាករសំខាន់ៗ)

- លទ្ធភាពរកចំណូល
- សង្ខេបតារាងតុល្យការ
- អនុបាតហិរញ្ញវត្ថុ
- ជំពូកផ្សេងៗ (ភាគលាភ ការគ្រប់គ្រងដើមទុន)

៧. ការវិភាគលទ្ធផល (សូចនាករសំខាន់ៗ)

- ការវិភាគលំអិតជំពូកនីមួយៗនៃប្រតិបត្តិការសំខាន់ៗ

៨. គោលដៅប្រតិបត្តិការអាជីវកម្ម

- ទស្សនៈវិស័យហិរញ្ញវត្ថុ
- ទស្សនៈវិស័យអតិថិជន
- ទស្សនៈវិស័យនៃដំណើរការត្រួតពិនិត្យផ្ទៃក្នុង
- ការអភិវឌ្ឍន៍ធនធានមនុស្ស
- ផែនការអាជីវកម្មសំខាន់ៗសម្រាប់ឆ្នាំក្រោយ

៩. គោលនយោបាយគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

- ហានិភ័យប្រតិបត្តិការ
- ហានិភ័យឥណទាន
  - ✓ ឥណទានមិនដំណើរការ
  - ✓ បំណុលកែលំអ
  - ✓ ហានិភ័យពីការប្រមូលឥណទាន (ហានិភ័យឥណទានធំៗ)
  - ✓ ហានិភ័យពីការថយចុះតម្លៃនៃវត្ថុបញ្ចាំ
- ហានិភ័យទីផ្សារ
  - ✓ ហានិភ័យពីការប្តូររូបិយប័ណ្ណបរទេស
  - ✓ ហានិភ័យអត្រាការប្រាក់
  - ✓ ហានិភ័យសាច់ប្រាក់ងាយស្រួល

១០. ការអះអាងរបស់គណៈគ្រប់គ្រងចំពោះរបាយការណ៍ហិរញ្ញវត្ថុ

១១. របាយការណ៍របស់ស្នងការគណនីឯករាជ្យ

១២. ព័ត៌មានស្តីពីការកាន់កាប់សន្លឹកហ៊ុន (បរិមាណ)

១៣. របាយការណ៍ហិរញ្ញវត្ថុរួមទាំងកំណត់សម្គាល់ចំពោះរបាយការណ៍ហិរញ្ញវត្ថុ

១៤. ភាគីតំណាងរបស់ធនាគារ (សាខាតំណាងនិងភាគីតំណាងអន្តរជាតិ)

- សាខាតំណាងនិងភាគីតំណាងអន្តរជាតិ

១៥. ការផ្លាស់ប្តូរសំខាន់ៗនៅក្នុងឆ្នាំ

១៦. របាយការណ៍ហិរញ្ញវត្ថុសង្ខេបរយៈពេលបីឆ្នាំ

- ការពិនិត្យមើលជារួម